កិច្ចការ២៦:៣០-២៧:១៣

សាវ័កប៉ុលសម្តែងថា កត្តាដែលព្រះគ្រីស្ទរស់ពីសុគតឡើងវិញ ជាកត្តាសំខាន់ជាទីបំផុត។

ដោយសារព្រះអម្ចាស់យេស៊ូវជាព្រះដ៏រស់ពីសុគតឡើងវិញ ទ្រង់នឹងយាងត្រឡប់មកផែនដីនេះម្តងទៀត ដើម្បីជំនុំជំរះមនុស្សលោក។ ទ្រង់យាងមកវិញដោយគង់លើបល្ល័ង្កស។ ឯអ្នកដែលត្រូវមកទទួលការកាត់ទោសពីព្រះអម្ចាស់យេស៊ូវ គឺជាអ្នកទោស។ ឯអ្នកទោសនោះទៀតសោត គឺខ្ញុំហើយនិងលោកអ្នកបងប្អូន។ លោកអ្នកអាចជ្រើសរើសទទួលជឿព្រះយេស៊ូវក្នុងជីវិតនេះ ឬមួយចាំបាច់ត្រូវឈរនៅចំពោះព្រះអម្ចាស់យេស៊ូវដោយតក់ស្លត់ នៅថ្ងៃជំនុំជំរះនៅពេលព្រះអង្គគង់នៅលើបល្ល័ង្កស។ ក៏លោកអ្នកបងប្អូនអាចឈរនៅចំពោះព្រះអង្គទុកចិត្តថា ព្រះអម្ចាស់យេស៊ូវប្រកាសថាយើងជាអ្នករួចខ្លួនដោយបានជឿដល់ព្រះអម្ចាស់យេស៊ូវកាលយើងនៅរស់។ សេចក្តីរស់ឡើងវិញ របស់ព្រះអម្ចាស់យេស៊ូវមានសារៈសំខាន់ ចំពោះមនុស្សដែលមិនទាន់ជឿដល់ព្រះអម្ចាស់យេស៊ូវ ក៏ដូចជាមនុស្សដែលជឿដល់ព្រះអម្ចាស់យេស៊ូវរួចហើយដែរ។

**៣០ នោះស្តេច ព្រមទាំងចៅហ្វាយស្រុក នឹងព្រះនាងបេរេនីស**
**ហើយនឹងអស់អ្នកដែលអង្គុយជាមួយ ក៏ក្រោកឡើង**
**៣១ កាលបានថយចេញផុតហើយ នោះក៏ពិភាក្សាគ្នាថា មនុស្សនេះមិនបានធ្វើអ្វី**

**គួរនឹងស្លាប់ ឬនឹងជាប់ចំណងសោះ ៣២ ហើយស្តេចអ័គ្រីប៉ាមាន**
**បន្ទូលទៅលោកភេស្ទុសថា មនុស្សនេះ បើមិនបានសូមរើក្តីដល់**
**សេសារទេ នោះនឹងលែងបាន (កិច្ចការ២៦:៣០-៣២)។**

ឥឡូវ សាវ័កប៉ុលបានធ្វើដំណើរចេញឆ្ពោះទៅទីក្រុងរ៉ូមហើយ។ កន្លងមក មានអ្នកដែលបន្ទោសសាវ័កប៉ុលថា តើហេតុអ្វីបានជាចាំបាច់លោកត្រូវរើក្តីថ្វាយព្រះរាជា មហារាជសេសារអូគូស្ទ អោយកាត់ក្តីដល់លោក។ ក្នុងហេតុការណ៍នេះ សាវ័កប៉ុលមិនមានការភាន់ច្រឡំទេ ក្នុងការរើក្តីទៅទូលដល់ព្រះរាជាសេសារអូគូស្ទវិញ។

ខ្ញុំហ៊ានអះអាងយ៉ាងដូច្នេះ ពីព្រោះពេលដែលលោកសរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងរ៉ូម លោកបញ្ជាក់យ៉ាងច្បាស់ថា "ព្រមទាំងសូមអង្វរជាដរាប ឱ្យខ្ញុំបានឱកាសស្រួលតាមព្រះហឫទ័យម្តងណោះ ដើម្បីនឹងមកឯអ្នករាល់គ្នា បើសិនជាបាន ដោយព្រោះខ្ញុំរឭកចង់ឃើញអ្នករាល់គ្នា ដើម្បីនឹងចែកអំណោយទានណាមួយ ខាងវិញ្ញាណមកអ្នករាល់គ្នា ប្រយោជន៍អោយអ្នករាល់គ្នាបានតាំងនៅយ៉ាងខ្ជាប់ខ្ជួន" (រ៉ូម ១:១០-១១)។ ឃ្លានេះមានន័យថា បើលោកមានឱកាសអាចទៅទីក្រុងរ៉ូមបាន លោកចង់ឃើញពួកជំនុំផ្ទាល់ភ្នែក ព្រមទាំងចង់បង្រៀនពីអំណោយទានដល់ពួកជំនុំនៅទីនោះ ដើម្បីអោយពួកអ្នកជឿអាចរឹងមាំក្នុងជំនឿ និងការអនុវត្តន៍ផ្ទាល់ខ្លួន។

ឥឡូវនេះ សាវ័កប៉ុលកំពុងធ្វើដំណើរឆ្ពោះទៅទីក្រុងរ៉ូម ដូចលោកបានអធិស្ឋានទូលសូមដល់ព្រះអង្គហើយ។ លោកអ្នកបងប្អូនចង់ដឹងថា តើដំណើររបស់

សាវ័កប៉ុល ចុះទៅទីក្រុងរ៉ូម មានសុវត្ថិភាព ឬមួយយ៉ាងណា។ គ្រូគង្វាលមួយរូប បានរៀបចំមេរៀនសម្រាប់បង្ហាត់ដល់ក្រុមយុវជន។ លោកបានហៅដំណើរដែលសាវ័កប៉ុលចេញទៅទីក្រុងយេរូសាឡិមលើកនេះថា ជាដំណើរដែលលោកទទួលដោយមានសុវត្ថិភាពជាទីបំផុត។ ដំណើរសាវ័កប៉ុលរាប់ថា មានសុវត្ថិភាព ទោះបីមានការលំបាក តែជាដំណើរដែលត្រូវនិងព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មានបំណងចង់អោយសាវ័កប៉ុលធ្វើដំណើរទៅកាន់ទីក្រុងរ៉ូម ដើម្បីធ្វើទីបន្ទាល់ពីទ្រង់។ ដល់ពួកជនដែលធ្វើការនៅដំណាក់មហារាជសេសារ និងព្រះរាជាសេសារអ្វគូស្ទផ្ទាល់។

# ជំពូក ២៧

***ឆាកចនា*** *សាវ័កប៉ុលធ្វើដំណើរទៅដល់ទីក្រុងរ៉ូមដោយសុវត្ថិភាព*
*ការឆ្លងកាត់ព្យុះសមុទ្រ*

ដំណើរចុងក្រោយបង្អស់ដែលសាវ័កប៉ុលចាកចេញពីសេសារា ឆ្ពោះទៅកាន់ទីក្រុងរ៉ូម យើងអាចហៅថា ជាដំណើរបេសកកម្មលើកទីបួន។ នៅពេលលោកធ្វើដំណើរលើកនេះ ទោះបីលោកជាប់ចំណងក៏ដោយ លោកនៅតែបំពេញកិច្ចការរបស់លោកដូចកាលលោកមានដៃនៅមានសេរីភាពដែរ។ ច្រវាក់ដែលជាប់ដៃលោក គ្មានឥទ្ធិពលអ្វីទេ។ លោកជាប់ច្រវាក់មែន ប៉ុន្តែព្រះបន្ទូលរបស់ព្រះមិនបានជាប់ច្រវាក់ឡើយ។ នៅពេលលោកសរសេរសំបុត្រទៅកាន់សិស្សរបស់លោកមួយរូបឈ្មោះ លោកធីម៉ូថេ លោកមានប្រសាសន៍ថា "ហើយខ្ញុំរងទុក្ខ ទាំងជាប់ចំណងដូចជាមនុស្សអាក្រក់ ដោយព្រោះដំណឹងល្អនេះឯង ប៉ុន្តែ ព្រះបន្ទូលមិនបានជាប់ចំណងទេ" (២ធីម៉ូថេ ២:៩)។ ម្យ៉ាងវិញទៀត លោកសរសេរទៅកាន់ពួកជំនុំនៅទីក្រុងភីលីពថា "បងប្អូនអើយ ខ្ញុំចង់ឱ្យអ្នករាល់គ្នាដឹងថា ការទាំងប៉ុន្មានដែលកើតឡើងដល់ខ្ញុំ នោះបានប្រែទៅជាចំរើនដល់ដំណឹងល្អវិញ" (ភីលីព១: ១២)។

ព្រះជាម្ចាស់នៅតែមានឧត្តមភាពនៅលើស្ថានការណ៍ ទាំងអម្បាលមាណដែលសាវ័កប៉ុលកំពុងឆ្លងកាត់។ ការធ្វើដំណើរចេញពីទីក្រុងយេរូសាឡិម ទៅទីក្រុងរ៉ូម

មិនមែនអស់លុយតិចទេ។ ប៉ុន្តែ ដោយសារសាវ័កប៉ុលត្រូវគេរាប់ថាជាអ្នកទោសរបស់រាជការរ៉ូម គេបញ្ជូនសាវ័កប៉ុលតាមនាវា ដោយមិនចាំបាច់អោយសាវ័កប៉ុលបង់ថ្លៃអ្វីឡើយ។ ដំណើរនេះ ជាសេចក្តីឆ្លើយតបដែលព្រះជាម្ចាស់ប្រទានមក ដោយសារសាវ័កប៉ុល បានអធិស្ឋានសូមអោយលោកបានធ្វើដំណើរទៅក្រុងរ៉ូម ដូចទ្រង់ព្រៀងទុក។

នៅពេលដែលសាវ័កប៉ុលសូមវិក្តីថ្វាយព្រះរាជាសេសារអូគូស្ទ អភិបាលខេត្តភេស្ទុសនិងព្រះរាជាអ័គ្រីប៉ា លែងមានអំណាចអ្វីនៅលើលោកទៀតហើយ។ បន្ទាប់ពីព្រះរាជាអ័គ្រីប៉ា ស្តាប់សេចក្តីអធិប្បាយរបស់សាវ័កប៉ុល ស្តេចអង្គនេះបានពិភាក្សាជាមួយនឹងលោកអភិបាលខេត្តភេស្ទុសថា "...បើមិនបានសូមវិក្តីដល់សេសារទេ នោះនឹងលែងបាន" (កិច្ចការ២៦:៣២)។ មកទល់ពេលនេះ លោកភេស្ទុសនិងព្រះរាជាអ័គ្រីប៉ា មិនអាចធ្វើអ្វីដល់សាវ័កប៉ុលបានទៀតទេ ពីព្រោះលោកត្រូវបញ្ជូនសាវ័កប៉ុលទៅទីក្រុងរ៉ូម។

ជំពូក២៧ គឺជាការកត់ត្រាហេតុការណ៍នានាតាមផ្លូវសមុទ្រដែលសាវ័កប៉ុលត្រូវឆ្លងកាត់ក្នុងដំណើរឆ្ពោះទៅកាន់ទីក្រុងរ៉ូម។ នៅលើលោកនេះ ការធ្វើដំណើរកាត់សមុទ្រមានគ្រោះថ្នាក់ខ្លាំងណាស់។ ប៉ុន្តែ គេមិនដែលបានកត់ត្រាយ៉ាងលំអិតទេ។ ដំណើរដែលសាវ័កប៉ុលទៅទីក្រុងរ៉ូម មានគ្រោះថ្នាក់នៅក្នុងសមុទ្រ។ មានគេកត់ត្រាដំណើរនេះយ៉ាងពិស្តារជាទីបំផុត។ អ្នកប្រាជ្ញមួយរូបនាម វៀលលីយ៉ុំរ៉ាមសេ បានវាយតម្លៃកំណត់ត្រារបស់បណ្ឌិតលូកាថា ជាឯកសារដែលមានធាតុពិតយ៉ាងខ្លាំងជា

ទីបំផុត។ គម្ពីរកិច្ចការជំពូក២៧ គឺជាឯកសារមួយដ៏សំខាន់ ដែលគេបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរប៊ីប។

បណ្ឌិតលូកាបង្កើតភាសាក្រេកជាពាក្យថ្មីៗច្រើនណាស់ ដើម្បីកត់ត្រារឿងរ៉ាវដែលកើតឡើង ទាក់ទងនឹងគ្រោះថ្នាក់សាវ័កប៉ុលឆ្លងកាត់តាមសំពៅ។ លោកចាំបាច់ត្រូវប្រើពាក្យក្រេកថ្មីៗ ពីព្រោះរឿងនោះមិនដែលមានគេកត់ទុកពីមុនមកឡើយ។

ឥឡូវ សូមយើងធ្វើដំណើរជាមួយនឹងសាវ័កប៉ុល ពេលដែលគាត់ធ្វើដំណើរឆ្លងតាមផ្លូវសមុទ្រដ៏ធំនេះ។ ដំណើរនេះ រាប់ថាជាដំណើរដែលធ្វើអោយយើងអរផងភ័យផង។

## សាវ័កប៉ុលធ្វើដំណើរដល់ទីក្រុងរ៉ូម ដោយសុវត្ថិភាព

**កាលបានសំរេចឱ្យយើងខ្ញុំចុះសំពៅចេញទៅឯស្រុកអ៊ីតាលី នោះគេក៏ប្រគល់ប៉ុល នឹងអ្នកទោសខ្លះទៀត ដល់មេទ័ពរងម្នាក់ឈ្មោះយូលាស ក្នុងកងទ័ពអូគូស្ទ (កិច្ចការ២៧:១)។**

សាវ័កប៉ុលចាប់ផ្តើមចេញដំណើរទីក្រុងសេសារា ក្នុងវត្ថុបំណងទៅប្រទេសអ៊ីតាលី និយាយអោយចំ គឺទីក្រុងរ៉ូម។ សាវ័កប៉ុលធ្វើដំណើរជាមួយនឹងពួកអ្នកទោស

ដទៃៗទៀត ដែលគេប្រគល់អោយនៅក្រោមបន្ទុករបស់មេទ័ពរងម្នាក់នាមយូលាស។ បើតាមខ្ញុំសន្និដ្ឋាន យើងយល់ថា សាវ៉កប៉ុល គឺជាមនុស្សមួយរូបគត់ ដែលមានសញ្ជាតិរ៉ូម នៅក្នុងចំណោមអ្នកទោសជាច្រើនរូប។ អ្នកទោសដទៃៗទៀត ជាអ្នកជាប់ទោសឧក្រិដ្ឋ ដែលគេបញ្ជូនទៅទីក្រុងរ៉ូម ដើម្បីធ្វើការប្រហារជីវិត។ សម័យនោះ ការប្រហារជីវិត មិនចាំបាច់ធ្វើដោយបាញ់សម្លាប់ ឬប្រការណាមួយទេ។ ការប្រហារជីវិតដល់អ្នកទោសឧក្រិដ្ឋ ដោយបោះអោយសត្វសាហាវស៊ីជាអាហារ។ នៅក្នុងសម័យសាសន៍រ៉ូមគ្រប់គ្រងពិភពលោកទាំងមូល គេតែងតែបញ្ជូនអ្នកទោសទាំងសំពៅៗទៅចិញ្ចឹមសត្វសឹង្ហ ដែលត្រៀមទុកអោយលេងសៀកនៅពហុកីឡដ្ឋានជាតិក្នុងទីក្រុងរ៉ូម។ ពួកអ្នកទោសទាំងនោះ គ្មានទីពឹងអ្វីក្រៅពីសេចក្តីស្លាប់ទេ។ ឆ្លៀតឱកាសដ៏មានតម្លៃនោះ សាវ៉កប៉ុលបានផ្សព្វផ្សាយដំណឹងល្អ ផ្តល់ទីសង្ឃឹមដល់អ្នកទោសដែលត្រូវគេបញ្ជូនយកទៅប្រហារជីវិត ដោយបោះអោយសត្វសឹង្ហស៊ី។ ព្រះអម្ចាស់យេស៊ូវរំឭកដល់យើងទាំងអស់គ្នាថា ព្រះអង្គទ្រង់យាងមកដើម្បីដោះអ្នកទោសអោយមានសេរីភាព។ អ្នកទោសទាំងអម្បាលមាណ ដែលជឿដល់ព្រះអម្ចាស់យេស៊ូវនៅលើសំពៅជាមួយនឹងសាវ៉កប៉ុល បានទទួលសេរីភាពខាងព្រលឹងវិញ្ញាណ ពីព្រោះព្រះអម្ចាស់ទ្រង់អត់ទោសដល់អំពើបាបរបស់គេ ព្រមទាំងលាងសម្អាតពិរុទ្ធភាពទាំងអម្បាលមាណ ដែលគេបានប្រព្រឹត្តក្នុងនាមខ្លួនគេជាជនឧក្រិដ្ឋ។

លោកមេទ័ពរងយូលាស មានសន្តានចិត្តល្អជាមួយនឹងសាវ៉កប៉ុល។

**យើងចុះសំពៅ១ពីស្រុកអាទ្រាមីត ដែលរៀបនឹងបើកទៅតាមឆ្នេរសមុទ្រស្រុកអាស៊ី ហើយក៏បើកទៅមានទាំងអើរីស្តាក ជាសាសន៍ម៉ាសេដូន ដែលនៅក្រុងថែស្សាឡូនីច ទៅជាមួយផង (កិច្ចការ២៧:២)។**

បើលោកអ្នកមានផែនទីម្តុំសមុទ្រមេឌីទែរ៉ាណេ លោកអ្នកអាចតាមដានមើលអំពីដំណើររបស់សាវ័កប៉ុល នោះលោកអ្នកឆាប់យល់ជាង។ ឥឡូវលោកចេញដំណើរពីទីក្រុងសេសារា ដោយគេបញ្ជាអោយសំពៅបើកអមឆ្នេរសមុទ្រនៃប្រទេសអ៊ីស្រាអែល។ សំពៅនោះ មិនធ្វើដំណើរត្រង់ កាត់ពុះចំកណ្តាលសមុទ្រមេឌីទែរ៉ាណេតែម្តងទេ ពីព្រោះខ្យល់ខ្លាំងណាស់ ហើយសម័យដើមក៏មិនមានសំពៅណាធំល្មម អាចទប់ទល់បានជាមួយនឹងរលកសមុទ្រដ៏ធំទាំងនោះបានផង។ ដូច្នេះ បានជាគេត្រូវធ្វើដំណើរអមឆ្នេរសមុទ្រប្រទេសអ៊ីស្រាអែលឡើងទៅជើង រួចហើយកាច់ទៅលិច អមឆ្នេរសមុទ្ររៀងរហូតទៅដល់ទឹកដីប្រទេសអ៊ីតាលី។

**ដល់ថ្ងៃស្អែក យើងបានចូលទៅចតនៅក្រុងស៊ីដូន នោះយូលាសបានប្រព្រឹត្តនឹងប៉ុលដោយសប្បុរស បានបើកឲ្យគាត់ទៅសួរពួកសំឡាញ់នឹងទទួលរបស់អ្វីដែលគេជូនដល់គាត់ដែរ (កិច្ចការ ២៧:៣)។**

ទីក្រុងស៊ីដូន និងទីក្រុងទីរ៉ូសជាទីក្រុងដែលយើងធ្លាប់ស្គាល់រួចមកហើយ។ ទីក្រុងទាំងពីរនេះ ស្ថិតនៅលើឆ្នេរសមុទ្រនៃស្រុកភេនីស ដែលសព្វថ្ងៃនេះហៅថា ប្រទេសល្បាណូន។

លោកមេទ័ពរងយូលាសផ្តល់សេរីភាពដល់សាវ័កប៉ុលខ្លាំងណាស់។ ខ្ញុំជឿថា លោកមេទ័ពរងរូបនេះ ប្រហែលជាទទួលជឿដល់ព្រះអម្ចាស់យេស៊ូវតាមសាវ័កប៉ុលផង ក៏មិនដឹង។ លោកអនុញ្ញាតអោយសាវ័កចុះសួរពួកសិស្ស ព្រមទាំងអនុញ្ញាតអោយសាវ័កប៉ុលទទួលជំនូនផ្សេងៗ ដែលពួកសិស្សបានជូនដល់លោក។ ការប្រកបគ្នារវាងអ្នកគ្រីស្ទបរិស័ទមានតម្លៃខ្លាំងណាស់ សូម្បីសាវ័កប៉ុល ដែលជាសាវ័កធំមួយក្នុងចំណោមអ្នក១២ ត្រូវការគ្រីស្ទបរិស័ទដទៃៗទៀត ដែលជាបងប្អូនរបស់លោក។ នៅលើលោកនេះ មិនមានគ្រីស្ទបរិស័ទណាមួយ ដែលមិនត្រូវការគ្រីស្ទបរិស័ទដទៃទៀតទេ។ យើងត្រូវការគ្នាទៅវិញទៅមកដោយខានមិនបាន ទោះពេលខ្លះយើងមានការខ្វែងមតិគ្នាយ៉ាងណាក៏ដោយ។

**យើងបើកពីទីនោះ សសៀរតាមកោះគីប្រុសទៅ ដោយព្រោះច្រាសខ្យល់ (កិច្ចការ២៧:៤)។**

ពាក្យថា សសៀរតាមកោះគីប្រុស មានន័យថា សំពៅត្រូវបើករវាងពីកើតកោះគីប្រុស សំដៅទៅទិសខាងជើង រួចហើយកាច់ខាងជើងកោះគីប្រុស សំដៅទៅ

ទិសខាងលិច គឺទៅទីក្រុងមីរ៉ា។ សំពៅចាំបាច់ត្រូវបើកកុងយ៉ាងដូច្នោះ ពីព្រោះខ្យល់ធ្លាក់ពីជើងមកខ្លាំងពេក។

**ក្រោយដែលបានឆ្លងកាត់សមុទ្រក្បែរស្រុកគីលីគា នឹងស្រុកប៉ាមភីលាផុតហើយ ក៏មកដល់មីរ៉ា នៅក្នុងស្រុកលូគា (កិច្ចការ ២៧:៥)។**

លើកមុន យើងបានធ្វើដំណើរជាមួយនឹងសាវ័កប៉ុល តាមផ្លូវសមុទ្រម្តងរួចមកហើយ។ ឥឡូវនេះ លោកកំពុងធ្វើដំណើរតាមឆ្នេរសមុទ្រខាងត្បូង ទ្វីបអាស៊ីចុងខាងលិចបង្អស់។ លោកធ្វើដំណើរតាមសំពៅដែលបើកសរសៀរតាមឆ្នេរសមុទ្រ។

**នៅទីនោះ មេទ័ពរកបានសំពៅ១ មកពីក្រុងអ៉ាលេក្សានទ្រា ដែលទៅស្រុកអ៊ីតាលី ក៏ឱ្យយើងជិះទៅ (កិច្ចការ២៧:៦។**

បើយើងមើលនៅក្នុងផែនទី យើងឃើញថា កោះមីរ៉ា គឺជាកោះដែលមិនគួរអោយសំពៅចុះសំចតនៅទីនោះទេ។ ប៉ុន្តែ សាវ័កប៉ុលចាំបាច់ត្រូវឈប់នៅទីនោះ ពីព្រោះគេត្រូវប្តូរសំពៅ ពីសំពៅតូចទៅសំពៅធំ ដើម្បីឆ្លងសមុទ្រមេឌីទែរ៉ាណេ។ សំពៅនោះមកទីក្រុងអ៉ាលេក្សានទ្រា ពោលគឺជាសំពៅដែលមកពីទ្វីបអាហ្វ្រិកខាងជើង។

សំពៅធំនោះ ក៏ធ្វើដំណើរទៅប្រទេសអ៊ីតាលីដែរ។

> **៧ កាលបើកបន្តិចៗទៅជាយូរថ្ងៃ ក៏មកទន្ទឹមនឹងគ្នីដុសដោយពិបាក
> ណាស់ ពីព្រោះខ្យល់មិនស្រួលសោះ នោះយើងបើកសសៀរចូល
> ទៅ តាមកោះក្រេត ទល់មុខនឹងជ្រោយសាលម៉ូន ៨ បើកទៅ
> តាមកោះនោះ ដោយពិបាកណាស់ ក៏ដល់កន្លែង១ហៅថា ទ្វារ
> សមុទ្រលំអ ដែលនៅជិតក្រុងឡាសេ (កិច្ចការ២៧:៧-៨)។**

នៅពេលនេះ គេបានបើកសំពៅសំដៅទៅកោះក្រេត។ បើតាមដំណើរនេះ ខ្យល់មិនស្រួលសោះ បានជាគេមិនអាចលើកក្ដោងអោយសំពៅធ្វើដំណើរតាមទិស ដែលគេចង់ទៅបាន។ ការធ្វើដំណើរច្រាសខ្យល់តាមសំពៅសម័យដើម ជាការលំបាកខ្លាំងណាស់។ ក្នុងករណីសាវ័កប៉ុល ខ្យល់បក់មិនប្រក្រតីធ្វើអោយគេពិបាកលើកក្ដោងសំពៅ ក៏វេរក្បាលឆ្ពោះទៅកំពង់ផែឡាសេវិញ។ កំពង់ផែឡាសេ គឺជាកំពង់ផែមួយដែលស្ថិតនៅឆ្នេរសមុទ្រខាង ត្បូងនៃកោះក្រេត។

> **លុះបានកន្លងមកជាយូរថ្ងៃ កាលសំពៅណាបើកទៅនឹងមាន អន្តរាយ ពីព្រោះបុណ្យតមបានកន្លងហើយ នោះប៉ុលទូន្មានគេថា (កិច្ចការ២៧:៩)។**

សេចក្តីខាងលើបញ្ជាក់ថា រដូវធ្វើដំណើរជិតផុតណាស់ហើយ។ ឯរដូវត្រជាក់ចាប់ផ្តើមធ្លាក់មកដល់សន្សឹម១។ បើគេចង់ធ្វើដំណើរទៅទីក្រុងរ៉ូម គេត្រូវធ្វើដំណើរនៅរដូវក្តៅ ពីព្រោះមិនសូវមានខ្យល់ព្យុះទេ។ សាវ័កប៉ុលរំឭកដល់មេទ័ព ព្រមទាំងអ្នកដើរជើងសមុទ្រទាំងអម្បាលមាណថា បើត្រូវចេញដំណើរនៅពេលនេះ គេត្រូវជួបជាមួយនឹងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរជាមិនខាន។ មេទ័ពហើយនិងពួកម្ចាស់សំពៅ នាំគ្នាគិតថា គេចង់ធ្វើដំណើរអោយទៅដល់ទីក្រុងរ៉ូមមុនរដូវខ្យល់ព្យុះ។ ដោយសារដំណើរនេះមើលទៅហាក់ដូចជាគ្រោះថ្នាក់ បានជាសាវ័កប៉ុលរំឭកដល់លោកទាំងនោះថា មិនគួរធ្វើដំណើរនៅក្នុងពេលនេះទេ។

> **"[10]អ្នករាល់គ្នាអើយ បើបើកទៅឥឡូវ ខ្ញុំយល់ឃើញថា នឹងមានអន្តរាយ ហើយខូចខាតជាច្រើន មិនត្រឹមតែទំនិញ នឹងសំពៅប៉ុណ្ណោះទេ គឺដល់ទាំងជីវិតយើងរាល់គ្នាផង "[11]ប៉ុន្តែ មេទ័ពបានទុកចិត្តនឹងអ្នកកាន់ចង្កូត ហើយនឹងម្ចាស់សំពៅ ជាជាងពាក្យដែលប៉ុលថានោះវិញ (កិច្ចការ២៧:១០-១១)។**

យើងយល់ហើយ ថាហេតុអ្វីបានជាលោកមេទ័ពមិនព្រមស្តាប់ដំបូន្មានរបស់សាវ័កប៉ុល។ ក្នុងនាមលោកជាមេទ័ពវង តើលោកចាំបាច់ត្រូវស្តាប់យោបល់អ្នកទោសធ្វើអ្វី។

ប៉ុន្តែសូមយើងយល់ថា សាវ័កប៉ុលមិនមែនជាមនុស្សសាមញ្ញធម្មតាទេ ពោលគឺលោកមានគំនិតរបស់ព្រះ។ លុះក្រោយមកទៀត ទើបលោកមេទ័ពយល់ថា បើធ្វើតាមដំបូន្មានរបស់សាវ័កប៉ុល នោះគេមិនមានគ្រោះថ្នាក់ដល់បែបនេះទេ។ ការត្រិះរិះពិចារណាខាងព្រលឹងវិញ្ញាណរបស់សាវ័កប៉ុល មានអទិភាពលើការយល់ដឹងរបស់មេទ័ព និងអ្នកដើរជើងសមុទ្រទាំងអម្បាលមាណ ដែលមានបទពិសោធន៍ខ្ពស់។ កត្តានេះបញ្ជាក់ថាទឹកចិត្តរបស់សាវ័កប៉ុល មិនមែនស្ថិតនៅក្រោមភាពទ័លច្រក ឬអារម្មណ៍របស់ក៏លោកមានការធុញថប់ឡើយ។ ដំបូន្មានដែលសាវ័កប៉ុលផ្តល់ដល់លោកមេទ័ព ហើយនិងម្ចាស់សំពៅ សបញ្ជាក់ថា ផ្លូវចិត្តរបស់សាវ័កប៉ុល មានភាពជ្រះថ្លាជានិច្ច។ លោកផ្តល់ពតិមានយ៉ាងច្បាស់លាស់ដល់លោកមេទ័ពថា រឿងនេះ ជារឿងមានគ្រោះថ្នាក់។ លោកមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់យ៉ាងពិតប្រាកដ បានជាលោកអាចត្រិះរិះពិចារណាមើលដំណើរនេះឃើញ។ ដូចហេតុការណ៍ជាក់ស្តែងដែលត្រូវកើតឡើង។

> **ហើយដោយព្រោះទ្វារសមុទ្រនោះ មិនស្រួលនឹងសំណាក់នៅក្នុងរដូវរងារផង បានជាច្រើនគ្នាគេទូន្មានឱ្យបើកចេញពីទីនោះទៅ ដើម្បីនឹងស្រួតទៅឯភេនីច ហើយឱ្យស្នាក់នៅក្នុងរដូវរងាវិញ បើសិនជាបាននោះជាទ្វារសមុទ្រនៅកោះក្រេត ដែលបែរទៅទិសនិរតីនឹងទិសពាយ័ព្យ (កិច្ចការ២៧:១២)។**

កោះក្រេត គឺជាកោះមួយដែលធំជាងគេបង្អស់ ស្ថិតនៅខាងត្បូងទ្វីបអាស៊ីចុងខាងលិច។ កោះនេះជាកម្មសិទ្ធិរបស់ប្រទេសក្រេក។ កោះនេះធំហើយមានកំពង់ផែល្អៗច្រើនណាស់ ដែលគេប្រើសម្រាប់ចតសំពៅចន្លោះទ្វីបអាហ្វ្រិកនិងទ្វីបអឺរ៉ុប។

អ្វីៗទាំងអស់ដែលកើតឡើង បញ្ជាក់ថាដំបូន្មានរបស់សាវ័កប៉ុល សុទ្ធតែត្រឹមត្រូវ។ នៅក្នុងដំណើរឆ្លងសមុទ្រទាំងមូល អ្នកបើកសំពៅ ទាហាននិងម្ចាស់សំពៅ សុទ្ធតែធ្វើការសន្និដ្ឋានទាំងអស់។ ចំណែកសាវ័កប៉ុលវិញ លោកសម្លឹងមើលទៅព្រះជាម្ចាស់ ដើម្បីអោយដឹងអំពីដំណើរដែលត្រូវប្រព្រឹត្តជាយ៉ាងណា។ ទាក់ទងនឹងដំណើរឆ្លងកាត់សមុទ្រលើកនេះ។

**ដូច្នេះ កាលមានខ្យល់បក់រំភើយៗមកពីទិសខាងត្បូង នោះគេស្មានថាបានដូចចិត្តហើយ ក៏ស្រាវយុថ្កាឡើង បើកទៅតាមក្បែរកោះក្រេត (កិច្ចការ២៧:១៣)។**

ដំណើរតាមផ្លូវសមុទ្រ ភាគច្រើនគឺជាដំណើរប៉ាន់ស្មាន។ គេនាំគ្នាស្មានថាដោយសារខ្យល់ធ្លាក់ពីត្បូងល្មៀកៗ ថាជារឿងល្អសម្រាប់គេ។ លោកមេទ័ពសម្លឹងមើលមនុស្ស ព្រមទាំងទុកចិត្តលើខ្លួនឯង ដើម្បីធ្វើដំណើរឆ្លងកាត់សមុទ្រ។ ចំណែកសាវ័កប៉ុល សម្លឹងមើលព្រះជាម្ចាស់។ នៅក្នុងគម្ពីរកិច្ចការ២៧:២៥ សាវ័កប៉ុលមានប្រសាសន៍ប្រាប់ដល់អ្នកទាំងអស់គ្នាថា "ពីព្រោះលោកជឿព្រះ" បានជាលោកអាចផ្តល់

ដំបូន្មានយ៉ាងត្រឹមត្រូវយ៉ាងដូច្នេះ។

ជីវិតរបស់មនុស្សប្រៀបដូចជាសមុទ្រ ឯជីវិតរបស់បុគ្គលម្នាក់ៗប្រៀបដូចជាទូក។ យើងអាចដឹកនាំជីវិតរបស់យើង តាមការសន្និដ្ឋានរបស់អ្នកដទៃក៏បានដែរ។ នៅក្នុងជីវិតយើង ពិតជាជួបប្រទះជាមួយនឹងព្យុះសង្ឃរា ពិតជាជួបប្រទះជាមួយនឹងរលកសមុទ្រយ៉ាងខ្លាំងជាមិនខាន។ ប្រាជ្ញារបស់មនុស្សលោក ដែលបានមកតាមរយៈការសិក្សាតាមរយៈបទពិសោធន៍ សុទ្ធតែជារឿងសន្និដ្ឋានទាំងអស់។ នៅលើលោកនេះមានមនុស្សរាប់ពាន់នាក់ ដែលប្រឹងប្រែង ដើម្បីកែស្ថានភាពពិភពលោកនេះអោយបានល្អប្រសើរឡើងវិញ។ ប៉ុន្តែ ពីរពាន់ឆ្នាំកន្លងទៅហើយ ស្ថានភាពនៅក្នុងសកលលោក បានកែប្រែមែនគឺ ពីល្អប្រសើរទៅអាក្រក់ទៅៗ។ យើងត្រូវការមនុស្ស ដែលមានគំនិតរបស់ព្រះ។ អ្នកវិទ្យានយោបាយដ៏ល្បីល្បាញមួយរូប នាមលោកហ្គតស្តូន មានប្រសាសន៍ថា "រដ្ឋបុរសរបស់ប្រទេសនីមួយៗត្រូវដឹងថា ហាសិបឆ្នាំខាងមុខ ប្រទេសរបស់លោកនឹងទៅជាយ៉ាងណា"។ បើរដ្ឋបុរសនីមួយៗមិនមានទស្សនៈវិស័យសម្រាប់ប្រទេសជាតិខ្លួនក្នុងរយៈពេលហាសិបឆ្នាំខាងមុខទេ អ្នកទាំងនោះមិនគួរធ្វើជាអ្នកដឹកនាំរបស់នគរឡើយ។ យើងអធិស្ឋានសូមអោយមានរដ្ឋបុរស ដែលចេះស្គាល់អនាគតរបស់ប្រទេសលោក ក្នុងរយៈពេលហាសិបឆ្នាំខាងមុខ។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"